# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល
សាលក្រមរដ្ឋប្បវេណីលេខ ១៨ "ន"
ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ នៅសាលសវនាការជាសាធារណៈនៃសាលាដំបូងខេត្តកណ្តាល លើសំណុំរឿងរដ្ឋប្បវេណីលេខ: ៤១៦ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ ដោយមានសមាសភាពដូចខាងក្រោម៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] អនុប្រធានសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

ដើមចោទឈ្មោះ [redacted] សុភ័ណ្ឌ ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted]។

មានកញ្ញាមេធាវី [redacted] និងកញ្ញាមេធាវី [redacted] អត្តលេខ ២០២៥T ជាអ្នកតំណាងដោយអាណត្តិ។

ចុងចម្លើយ គ្មាន។

### អង្គហេតុ និងចំណុចវិវាទ

១-ការទាមទាររបស់ដើមចោទ

**ដើមចោទទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារ៖**

-បញ្ជាក់អត្ថិភាពនៃសិទ្ធិរបស់ឈ្មោះ [redacted] សុភ័ណ្ឌ ជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើដីមួយកន្លែងទំហំ ១៣៣៩៤ (ដប់បីពាន់បីរយកៅសិបបួន) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិព្រែកតាកែវ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០១៩៨១៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥។

**២-អង្គហេតុដែលជាមូលហេតុនៃការទាមទាររបស់ដើមចោទ**

ដើមចោទបានប្តឹងថា ខ្លួនបានទិញដីដែលមានទីតាំងដូចរៀបរាប់ខាងលើនេះ ពីឈ្មោះ [redacted] គន តាមលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ០០២/សកស ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១២ និងបានបំពេញនីតិវិធីស្នើសុំប័ណ្ណកម្មសិទ្ធិពីការិយាល័យរៀបចំដែនដី នគរូបនីយកម្មសំណង់ និងភូមិបាលស្រុកកៀនស្វាយ ចប់សព្វគ្រប់នៅឆ្នាំ២០១៥។ ទោះបីជាខ្លួនមិនបានរស់នៅលើទីតាំងដីនោះ តែខ្លួនបានដាំដំណាំជាច្រើន ទើបតែពេលថ្មីៗនេះ ខ្លួនបានទទួលដំណឹងពីអ្នកស្រុកដែលនៅក្បែរនោះ ថាមានបុគ្គលដែលមិនស្គាល់អត្តសញ្ញាណបានមកអះអាងថានោះជាដីរបស់គេទៅវិញ។ ដូច្នេះដើម្បីជៀសវាងការខូចខាតផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងបញ្ជាក់ឱ្យកាន់តែច្បាស់អំពីសិទ្ធិលើកម្មសិទ្ធិស្របច្បាប់របស់ខ្លួន ទើបខ្លួនសម្រេចដាក់ពាក្យប្តឹងមកតុលាការដើម្បីសុំសាលក្រមបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើដី។



Scanned with CamScanner

៣.ការអះអាងរបស់ភាគី

ក-ដើមចោទឈ្មោះ [redacted] សុភ័ណ្ឌ មានមេធាវី [redacted] និងមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ អះអាងថា៖សុំបញ្ជាក់អត្ថិភាពនៃសិទ្ធិលើដីមួយកន្លែងទំហំ ១៣៣៨៤ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅ ភូមិព្រែកតាកែវ ឃុំសំរោង ស្រុកកៀនស្វាយ ខេត្តកណ្ដាល សម្គាល់ដោយប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០១៩៨១៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ដោយអះអាងថា៖ កូនក្ដីនាងខ្ញុំបានទិញដីដែលមានទីតាំងដូចរៀបរាប់ខាងលើនេះ ពីឈ្មោះ [redacted] គន តាមលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ០០២/សកស ចុះថ្ងៃទី០៦ ខែ មករា ឆ្នាំ២០១២ និងបានបំពេញនីតិវិធីស្នើសុំប័ណ្ណកម្មសិទ្ធិពីការិយាល័យរៀបចំដែនដី នគរូបនីយកម្មសំណង់ និងភូមិបាលស្រុកកៀន ស្វាយ ចប់សព្វគ្រប់នៅឆ្នាំ២០១៥។ ទោះបីជាកូនក្ដីនាងខ្ញុំមិនបានរស់នៅលើទីតាំងដីនោះ តែកូនក្ដីនាងខ្ញុំបានដាំដំណាំជា ច្រើន ទើបតែពេលថ្មីៗនេះ កូនក្ដីនាងខ្ញុំបានទទួលដំណឹងពីអ្នកស្រុកដែលនៅក្បែរនោះ ថាមានបុគ្គលដែលមិនស្គាល់អត្ត សញ្ញាណបានមកអះអាងថានោះជាដីរបស់គេទៅវិញ។ ដូច្នេះដើម្បីជៀសវាងការខូចខាតផលប្រយោជន៍ស្របច្បាប់របស់ កូនក្ដីនាងខ្ញុំ និងបញ្ជាក់ឲ្យកាន់តែច្បាស់អំពីសិទ្ធិលើកម្មសិទ្ធិស្របច្បាប់របស់កូនក្ដីនាងខ្ញុំ។

**៤.អំពីភស្តុតាង**

-បានឃើញ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០១៩៨១៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥។

-បានឃើញ លិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១២។

-បានឃើញ លិខិតបញ្ជាក់ពត៌មានសុរិយោដី ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០។

-បានឃើញ លិខិតធានាអះអាងលើតម្លៃដី ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០។

៥-ក្នុងរឿងនេះ៖ **ពុំមានចំណុចវិវាទទេ។**

## សំអាងហេតុ

**តាមការសាកសួរភាគីដើមចោទ និងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖**

១-ផ្អែកតាមការទាមទារ និងតាមការអះអាងរបស់អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ កញ្ញាមេធាវី [redacted] និងកញ្ញាមេធាវី [redacted] ថាកូនក្ដីរបស់ខ្លួនបានទិញដីពីឈ្មោះ [redacted] គន តាមលិខិតផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លីលេខ ០០២/សកស ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១២។ អំឡុងឆ្នាំ២០១៥ កូនក្ដីរបស់ខ្លួនបានស្នើសុំធ្វើប្លង់រឹង ដោយបានបំពេញបែបបទ និងគ្រប់នីតិវិធីនៅការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកកៀនស្វាយចប់សព្វគ្រប់ ក្រោយមកក៏ទទួលបានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០១៩៨១៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ យ៉ាងត្រឹមត្រូវស្របច្បាប់។ ចាប់តាំងពីទិញដីខាងលើរួចមក កូនក្ដីរបស់ខ្លួនឈ្មោះ [redacted] សុភ័ណ្ឌ បានដាំដំណាំបន្ថែមនៅលើដីនោះ ទោះបីជាកូនក្ដីរបស់ខ្លួនពុំបានរស់នៅលើដីនោះក៏ដោយ។ ប៉ុន្តែគាត់តែងតែឡើងចុះមើលការខុសត្រូវលើដីរបស់គាត់ជាញឹកញ៉ាប់។ ម្យ៉ាងទៀត ពេលដែលអ្នកភូមិរស់នៅជិតខាងដីមានរវល់បុណ្យទាន ឬកម្មវិធីផ្សេងៗទៀត ពួកគាត់តែងតែសុំអនុញ្ញាតពីកូនក្ដីរបស់ខ្លួនដើម្បីសុំកន្លែងរៀបចំកម្មពិធីជាអាទិ៍។ ប៉ុន្តែស្រាប់តែពេលថ្មីៗនេះ កូនក្ដីខ្លួនបានទទួលដំណឹងពីអ្នកស្រុកនៅក្បែរដីរបស់គាត់ថា មានបុគ្គលមិនស្គាល់អត្តសញ្ញាណមកប្រាប់អ្នកភូមិផងរបងជាមួយថា ដីរបស់កូនក្ដីខ្លួនជាដីរបស់គេទៅវិញ។ កូនក្ដីរបស់ខ្លួនពិតជាមានការបារម្ភថា អាចនឹងមានបុគ្គលទុច្ចរិតមកបំពានសិទ្ធិជាកម្មសិទ្ធិកររបស់កូនក្ដីរបស់ខ្លួន។ ដូច្នេះដើម្បីជៀសវាងការខូចខាត



Scanned with CamScanner

ផលប្រយោជន៍ស្របច្បាប់របស់កូនក្តីរបស់ខ្លួន និងសុំបញ្ជាក់ឱ្យកាន់តែច្បាស់អំពីសិទ្ធិដែលជាកម្មសិទ្ធិករស្របច្បាប់លើដីដែលគាត់ទិញ និងកាន់កាប់ដោយស្របច្បាប់ ។ ការអះអាងនេះមានហេតុផលគ្រប់គ្រាន់អាចឱ្យតុលាការពិចារណាបាន។

២-លិខិតបញ្ជាក់ពត៌មានសុរិយោដីលេខ ៤៨៣៨/២០ ដនសស/អភិសុ ចុះថ្ងៃ០៧ ខែមេសា ឆ្នាំ២០២០ របស់ប្រធានមន្ទីរសុរិយោដីខេត្តកណ្តាល ដែលបញ្ជាក់ថា អចលនវត្ថុ ក្បាលដីលេខ G<sub></sub>VIII-០៤៦០ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ស្ថិតនៅភូមិព្រែកតាកែវ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ជារបស់ឈ្មោះ [redacted] សុភ័ណ្ឌ (ជាប្តីនាង [redacted] ណារី) ពិតជាបាន ចុះបញ្ជីនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោ ខេត្តកណ្តាល ពិតប្រាកដមែន និងពុំមានជាប់បន្ទុកអ្វីឡើយ។ តាមលិខិតបញ្ជាក់នេះ បង្ហាញឱ្យឃើញថា ឈ្មោះ [redacted] សុភ័ណ្ឌ ពិតជាបានបំពេញបែបបទស្នើសុំចុះបញ្ជីនូវដីមួយកន្លែងនេះ ត្រឹមត្រូវតាមច្បាប់ភូមិបាលរួចហើយ។

៣-តាមប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០១៩៨១៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ មានទីតាំងស្ថិតនៅភូមិព្រែកតាកែវ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល បង្ហាញឱ្យឃើញថាកម្មសិទ្ធិករនៃដីគឺឈ្មោះ [redacted] សុភ័ណ្ឌ ពិតប្រាកដមែន។

៤-តាមការទាមទារ និងការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] សុភ័ណ្ឌ និងភស្តុតាងដាក់ជូនតុលាការពិនិត្យ ឃើញថា ដើមចោទឈ្មោះ [redacted] សុភ័ណ្ឌ ពិតជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុលេខ ក.ណ ០១៩៨១៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ប្រាកដមែន។ ដូច្នេះ គប្បីតុលាការទទួលស្គាល់តាមការទាមទាររបស់ដើមចោទឈ្មោះ [redacted] សុភ័ណ្ឌ។

៥-ប្រាក់ប្រដាប់ក្តី គប្បីតុលាការសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធី រដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-បញ្ជាក់ថាដើមចោទឈ្មោះ [redacted] សុភ័ណ្ឌ ជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើដីមួយកន្លែងទំហំ ១៣៣៩៤ (ដប់បីពាន់បីរយកៅសិបបួន) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិព្រែកតាកែវ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល សម្គាល់ដោយប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០១៩៨១៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍១០កើត ខែស្រាពណ៍ ឆ្នាំជូតទោស័ក ព.ស.២៥៦៤

កណ្តាល,ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

កណ្តាល,ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner